ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៤ សរណន

# សារាចរណែនាំ

## ស្តីពី

## ការចាត់តាំងខួបលើកទី៣៦ ទិវាជនមានពិការភាពអន្តរជាតិ និងខួបលើកទី២០ ទិវាជនមានពិការភាពកម្ពុជា

## ក្រោមប្រធានបទ លើកកម្ពស់សិទ្ធិជនមានពិការភាព ធានាដល់ការធ្វើបរិយាប័ន្ន និងសមភាព

## ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៨

ជារៀងរាល់ឆ្នាំ ព្រះរាជាណាចក្រកម្ពុជាតែងប្រារព្ធទិវាជនមានពិការភាពកម្ពុជា និងទិវាជនមានពិការភាពអន្តរជាតិ ថ្ងៃទី៣ ខែធ្នូ ដើម្បីអបអរសាទរសមិទ្ធផលដែលរាជរដ្ឋាភិបាលកម្ពុជារួមគ្នាជាមួយគ្រប់ដៃគូពាក់ព័ន្ធសម្រេចបាននូវការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ និងបន្តបង្ហាញអំពីឆន្ទៈយកចិត្តទុកដាក់ជាអាទិភាពរបស់រាជរដ្ឋាភិបាលលើវិស័យពិការភាព ជាពិសេស ការគិតគូរពីសុខុមាលភាពបងប្អូនមានពិការភាពកម្ពុជា ឱ្យស្របតាមអនុសញ្ញាស្តីពីសិទ្ធិជនពិការ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក យុទ្ធសាស្ត្រអ៊ីនឈាន់ "**ធ្វើឱ្យសិទ្ធិក្លាយជាការពិត**" ក៏ដូចជា ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨។

ទិវាជនមានពិការភាពអន្តរជាតិត្រូវបានប្រារព្ធឡើង ដើម្បីរំលឹកអំពីការគេស៊ូទាមទារសិទ្ធិចូលរួមក្នុងសង្គមរបស់ជនមានពិការភាពប្រមាណ ១.៥ប៊ីលាននាក់ នៃប្រជាជនសរុបនៅក្នុងពិភពលោក ដែលជាជនបាត់បង់កាយសម្បទាកាយវិញ្ញាណ និងសតិបញ្ញា ដែលតែងតែជួបប្រទះឧបសគ្គរាំងក្នុងជីវិតតាំងពីឆ្នាំ១៩៥០ រហូតដល់បច្ចុប្បន្ន សំដៅធ្វើការផ្លាស់ប្តូរនូវស្ថានភាពរស់នៅរបស់ពួកគេ និងបង្កើនការយល់ដឹងអំពីបញ្ហាពិការភាព ដោយផ្តោតសំខាន់លើសិទ្ធិជនមានពិការភាព ព្រមទាំងការធ្វើសមាហរណកម្មជនមានពិការភាពទៅក្នុងគ្រប់សកម្មភាពនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ និងកីឡា។

ដោយឡែក ព្រះរាជាណាចក្រកម្ពុជាប្រារព្ធទិវាជនមានពិការភាពឡើង ដើម្បីរំលឹកអំពីមហាវិនាសកម្មនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានបន្សល់ទុកនូវផលវិបាកជាច្រើន ក្នុងនោះរួមមាន៖ ជនមានពិការភាព ស្ត្រីមេម៉ាយ កុមារកំព្រា ហើយមរតកនៃសង្គ្រាមនេះបានបន្សល់ទុកនូវគ្រាប់មីននិងកាកសំណល់ជាតិផ្ទុះជាច្រើនរាយប៉ាយពាសពេញផ្ទៃប្រទេស ពិសេសគ្រាប់បែកចង្កោមមានផ្ទុកសារជាតិគីមី ដែលបានរកឃើញជាច្រើននៅខេត្តស្វាយរៀង។ ក្រៅពីនោះ ប្រជាជនកម្ពុជាក៏ប្រឈមនឹងភាពរងគ្រោះមួយចំនួនទៀតដែលនាំឱ្យមានពិការភាព ដូចជា៖ គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ការងារ ពិការភាពពីកំណើត ចាស់ជរា ជំងឺរ៉ាំរ៉ៃ និងមូលហេតុផ្សេងៗទៀត។

ដើម្បីអបអរសាទរទិវាជនមានពិការភាពកម្ពុជាលើកទី២០ និងទិវាជនមានពិការភាពអន្តរជាតិលើកទី៣៦ ឆ្នាំ២០១៨ នេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំចាត់តាំងដូចតទៅ៖

១-ទិវាជនមានពិការភាពកម្ពុជាលើកទី២០ និងទិវាជនមានពិការភាពអន្តរជាតិលើកទី៣៦ ត្រូវប្រារព្ធក្រោមប្រធានបទ "**លើកកម្ពស់សិទ្ធិជនមានពិការភាព ធានាដល់ការធ្វើបរិយាប័ន្ន និងសមភាព**"។

២-ក្រសួងព័ត៌មានត្រូវសហការជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការ ណែនាំប្រព័ន្ធឃោសនារដ្ឋ និងឯកជនឱ្យធ្វើការផ្សព្វផ្សាយដល់សង្គមជាតិទាំងមូលបានយល់ជ្រួតជ្រាបអំពីប្រវត្តិនៃទិវាជនមានពិការភាពកម្ពុជា និងទិវាជនមានពិការភាពអន្តរជាតិ ៣ធ្នូ។

៣-គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវរៀបចំពិធីមីទ្ទិញ ពិធីជួបសំណេះសំណាលជាមួយជនមានពិការភាព កម្មវិធីកម្សាន្តសប្បាយរបស់ជនមានពិការភាព នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសិក្សារដ្ឋ ឯកជន អង្គការមិនមែនរដ្ឋាភិបាល និងគ្រប់មណ្ឌលនៅក្នុងមូលដ្ឋានរៀងៗខ្លួន។

៤-ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា មូលនិធិជនពិការ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិនិងអន្តរជាតិ សាលារាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធត្រូវសហការរៀបចំពិធីមីទ្ទិញថ្នាក់ជាតិ និងរៀបចំកម្មវិធីកម្សាន្តផ្សេងៗសម្រាប់ជនមានពិការភាពនៅរាជធានីភ្នំពេញ។

៥-គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈ ឯកជន ត្រូវរៀបចំចងបដា ពាក្យស្លោក ដើម្បីអបអរសាទរទិវាជនមានពិការភាពកម្ពុជាលើកទី២០ និងទិវាជនមានពិការភាពអន្តរជាតិលើកទី៣៦ ដែលមានខ្លឹមសារដូចខាងក្រោម៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- លើកកម្ពស់សិទ្ធិជនមានពិការភាព ធានាដល់ការធ្វើបរិយាប័ន្ន និងសមភាព
- រុះរើរបាំងឧបសគ្គនានា ដើម្បីបង្កើនឱកាសដល់ជនមានពិការភាព
- រួមគ្នាលើកកម្ពស់សិទ្ធិជនមានពិការភាព ដោយឈប់ប្រើពាក្យអសុរសលើជនមានពិការភាព
- បញ្ឈប់ការកេងប្រវ័ញ្ចគ្រប់រូបភាពលើជនមានពិការភាព ដើម្បីសង្គមមួយមានសិទ្ធិស្មើគ្នា
- ថ្ងៃនេះ ថ្ងៃស្អែក កុំឱ្យមានពិការភាពដោយគ្រោះថ្នាក់ចរាចរណ៍

ទទួលបានសារាចរណែនាំ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីរាជធានី ខេត្តត្រូវរៀបចំចាត់តាំងអនុវត្តក្នុងស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ច័ន្ទ ១១ រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ